# សារីន (Sarin)

## អ្វីទៅដែលហៅថា សារិន?



សារីន គឺជាជាតិគីមី សហារដែលមនុស្សផលិតឡើង។ គេអាចយកមកប្រើជាអាវុធគីមី។

## តើខ្ញុំប៉ះជាតិសារីន តាមរបៀបណា?

បើគេវកប្រើសារីនជាអាវុធ វាអាចមានភាពដូចជាៈ

- ឧស្ម័នដែលអ្នកដកដង្ហើមស្រូបចូល
- វត្ថុរាវដែលដាក់ក្នុងអាហារ ឬទឹក ឬ
- អ្វីមួយដែលអ្នកប៉ះ

សារីន ជាវត្ថុរាវដែលគ្មានពណ៌គ្មានក្លិនឬរសជាតិ។ ហើយវត្ថុរាវនោះក្លាយជាឧស្ម័នយ៉ាងឆាប់រហ័ស។

## រោគសញ្ញានៃជាតិពុលរបស់សារីន យ៉ាងដូចម្តេច?

រោគសញ្ញាទាំងនេះមានរួមដោយៈ

- ហៀរសំបោរ,ចេញទឹកភ្នែក
- មានចំណុចតូចនៅក្នុងប្រស្រីភ្នែក,ឈឺភ្នែក,ស្រវាំងភ្នែក
- ហៀរទឹកមាត់ និងចេញញើស
- ក្អក,តឹងទ្រូង,ដង្ហើមញាប់
- រាគ, ឧស្សាហ៍នោម
- ភ័ន្តភាំង,វិលមុខ,ខ្សោយទៅៗ
- ឈឺក្បាល,ធីងធោង,ចង្អោរ, និងឬចុកពោះ
- ធ្វើឲ្យបេះដូងដើរលឿន ឬញាប់ បន្ថយសម្ពាធឈាម។

ប្រសិនបើ អ្នក**ស្រូប**ជាតិសារីន រោគសញ្ញាដំបូងនឹងកើតមានឡើងនៅក្នុងកំឡុងពេលពីរបីវិនាទីក្រោយមក។

ប្រសិនបើ អ្នក**លេប**ជាតិសារីន រោគសញ្ញាដំបូងនឹងកើតមានឡើងនៅក្នុងកំឡុងពេល១៨ម៉ោងក្រោយមក។

បើជាតិសារីនសារិន **ប៉ះ**នឹងស្បែក អ្នកនឹងបែកញើសខ្លួនរបស់អ្នកនឹងកន្ត្រាក់។

## តើខ្ញុំនឹងត្រូវស្លាប់ ប្រសិនបើមានពុលនឹងជាតិសារីន?

មែនហើយ, ប្រសិនបើជាតិពុលវាចូលច្រើន។ លោកអ្នកជាសះស្បើយប្រសិនបើជាតិវាមានតិចតួច។

## តើខ្ញុំធ្វើយ៉ាងប្រសិនបើមានប៉ះនឹងជាតិសារីន នេះ?

**ហៅទៅលេខ 911។** ជំរាបប្រាប់គេអំពីអ្វីដែលបានកើតឡើង នឹងទីកន្លែងដែលអ្នកឋិតនៅ។

ប្រសិនបើអ្នក**លេប**ចូលនូវជាតិពុលសារីន នេះ



- **ហៅទៅលេខ 911។**
- កុំផឹកអ្វីឲ្យសោះ។
- **កុំខំធ្វើឲ្យចង្អោរ។**

ប្រសិនបើអ្នកដកដង្ហើម**ស្រូបចូល ឬប៉ះ**ជាតិ សារិន ត្រូវធ្វើដូចនេះជាប្រញាប់ៈ

- ○ **ចៀសពីកន្លែងនោះ ឲ្យឆ្ងាយ។** ប្រសិនបើនៅខាងក្រៅចាកចេញពីកន្លែងនោះ។ បើនៅខាងក្នុងត្រូវចេញទៅក្រៅ។ សារិនវាហុយតែផ្នែកខាងក្រោមទាបក្បែរដី ដូច្នេះសូមទៅកន្លែងណាដែលខ្ពស់ផុតពីដី។
- ○ **ដោះសម្លៀកបំពាក់ខាងក្រៅចេញ។** កុំដោះរំលងក្បាល- **កាត់វាចោលជាការល្អ។** កុំប៉ះសម្លៀកបំពាក់នោះតទៅទៀត ព្រោះវាមាននៅសល់ជាតិសារីន នេះ។
- ○ **លាងខ្លួន។ប្រើទឹកនិងសាប៊ូ** ប្រសិនមានរលាកឬស្រវាំងភ្នែក លាងទឹកធម្មតាពី10ទៅ15នាទី។
- ○ **យកសម្លៀកបំពាក់ទៅចោល** បន្ទាប់ពីបានលាងខ្លួន,ត្រូវ ប្រើស្រោមដៃជ័រឬថង់ជ័រច្រកសម្លៀកបំពាក់នោះទៅក្នុងថង់, ហើយត្រូវច្រករបស់ទាំងអស់ដែលប៉ះជាមួយសម្លៀកបំពាក់ទៅក្នុងថង់នោះដែរ។
- ○ **ចងថង់នោះ ឲ្យបានជិត។**យកថង់នោះទៅច្រកចូលក្នុងថង់**មួយទៀត។** ប្រាប់ដល់បុគ្គលិកផ្នែកអាសន្ននូវទីកន្លែងដែលអ្នកទុកថង់នោះ។



## ពត៌មានបន្ថែម...

ទូរស័ព្ទទៅ CDC: ទទួលជំនួយជាភាសាអង់គ្លេស ឬស្ប៉ាញ៉ុលៈ

800-CDC-INFO (800-232-4636)

888-232-6348 (TTY)

ឬចូលទៅបណ្តាញ: www.cdc.gov/sarin

www.dhs.ca.gov/epo